ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ: ៨៩ "ខ"ក្រ៧

ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ២០០១

ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១

-ស៊ើបសួរលេខ ១៥០២

ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១

ជំនុំជម្រះលេខ: ៤៣៩៦

ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈ នាថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ០៨ និង៣០ នាទីព្រឹក នៅសាលសវនាការទី៣ ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោកចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា

-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

-លោកស្រីចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ២០០១ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ:

១-ឈ្មោះ [redacted] វិច្ឆិកា ហៅខ្មៅ ភេទប្រុស អាយុ២៩ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើត ភូមិត្រ[redacted] ខេត្តតាកែវ កំរិតវប្បធម៌ថ្នាក់ទី៥ សាសនាព្រះពុទ្ធ មុខរបរ បើករថយន្ត ទីលំនៅមុនពេលឃុំខ្លួននៅឃ្លាំងអេតចាយ ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ ស៊ុង "ស្លាប់"ម្តាយឈ្មោះ [redacted] ង៉ា"ស្លាប់" ប្រពន្ធឈ្មោះ [redacted] សាវី កូន១នាក់ ជានីតិជន ទោសពីមុន គ្មាន។

**-ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១)** តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៤៩៥ "ស"ដឃដ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-ដោយមាន លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វិច្ឆិកា។

២-ឈ្មោះ [redacted] សារ៉េន ហៅចាម ភេទប្រុស កើតថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៨៣ អាយុ៣៩ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើត ឃុំ[redacted] ខេត្តព្រៃវែង សាសនាព្រះពុទ្ធ អាសយដ្ឋានរស់នៅភូមិសង្កែចុង ឃុំក្រាំងស្វាយ ស្រុកព្រះស្ដេច ខេត្តព្រៃវែង ជា **នីតិជន ទោសពីមុន គ្មាន**។ (ក្រៅឃុំ)

**-ដីកាបង្គាប់ឱ្យចាប់ខ្លួន** លេខ៧៣១ "ស"ដចន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

៣-ឈ្មោះ [redacted] ចន្ថា ភេទស្រី កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៨៨ អាយុ៣៥ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ សាសនា ព្រះពុទ្ធ អាសយដ្ឋានរស់នៅភូមិសង្កែចុង ឃុំក្រាំងស្វាយ ស្រុកព្រះស្តេច ខេត្តព្រៃវែង ជា នីតិជន ទោសពីមុន គ្មាន។ (ក្រៅឃុំ)

-**ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ** ៧៣០ "ស"ដចន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ។

-ដោយមាន លោកមេធាវី [redacted] ជា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] សារ៉េន និងឈ្មោះ [redacted] ចន្ថា។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុច ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **លឹមអ៊ាង** ភេទប្រុស អាយុ៤១ ឆ្នាំ ជនជាតិ ខ្មែរ មានអាសយដ្ឋានរស់នៅ ឃ្លាំងលេខ៨៨ ផ្លូវលេខ២១៧ ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

-ដោយមាន លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] **លឹមអ៊ាង**។

## <u>**អង្គហេតុនៃរឿងមានដូចតទៅ**</u>

កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង១៩ និង០០ នាទី ស្ថិតនៅភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជនរងគ្រោះឈ្មោះ [redacted] **លឹមអ៊ាង** ភេទប្រុស ឱ្យជនជាប់ចោទឈ្មោះ [redacted] **វិច្ឆិកា** ដឹកកំប៉ុងអាលុយមីញ៉ូមគ្រីបរួចទម្ងន់ **២៨**តោនមានតម្លៃ **៥០,០០០(ប្រាំម៉ឺន)**ដុល្លារអាមេរិក ចេញពីភូមិម៉ល។ លុះដល់ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង៧ និង០០ នាទី ជនជាប់ចោទឈ្មោះ [redacted] **វិច្ឆិកា** បានលួចយកកំប៉ុងអាលុយមីញ៉ូមនិងបានទូរស័ព្ទប្រាប់ ឈ្មោះ [redacted] ប៊ុនណា ថាមានគេដាក់ថ្នាំយកឥវ៉ាន់អស់ ជនរងគ្រោះ [redacted] **លឹមអ៊ាង** បានសួររកទីតាំងដែលជនជាប់ចោទឈ្មោះ [redacted] **វិច្ឆិកា** កំពុងនៅហើយជនជាប់ចោទរូបនេះបានប្រាប់ថានៅលើផ្លូវជាតិលេខ៦A ភូមិបាខម ឃុំសំពងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ជនរងគ្រោះបានទៅដល់ទីនោះនិងរាយការណ៍ទៅសមត្ថកិច្ចស្រុកជើងព្រៃ ខេត្តកំពង់ចាម ឱ្យជួយចុះមកអន្តរាគមន៍ឃាត់ខ្លួនជនជាប់ចោទ ឈ្មោះ [redacted] **វិច្ឆិកា** បញ្ជូនមកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី។ ក្រោយពីការស្រាវជ្រាវបន្ថែមរបស់អធិការនគរបាលខណ្ឌដង្កោ តាមរបាយការណ៍លេខ ០១១/២១ របក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ បានបញ្ជាក់ថាករណីលួចនេះ គឺមានពាក់ព័ន្ធជាមួយជនជាប់ចោទ ឈ្មោះ [redacted] **សារ៉េន** ភេទប្រុស និងឈ្មោះ [redacted] **ចន្ថា** ភេទស្រី។

-**បានឃើញ** របាយការណ៍សំយោគលេខ ០៤០/២១ រ.ប.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១ របស់អធិការនគរបាលខណ្ឌដង្កោ។

-**បានឃើញ** របាយការណ៍លេខ ០១១/២១ របក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ របស់អធិការនគរបាលខណ្ឌដង្កោ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ១៥៤៥ អ.យ.ដ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៤០៥៤ អ.យ.ដ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។



Scanned with CamScanner

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខ៥៤៥៥ "ស".ដ.ជ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា បានឆ្លើយថា ខ្លួនជាកម្មករនៅក្នុងឃ្លាំងអេតចាយ ហើយបានស្នាក់នៅទីនោះអស់រយៈពេលជិតមួយខែមកហើយ ខ្លួនមកធ្វើការនេះតាមរយៈឈ្មោះ ឌីណា ត្រូវជាប្អូនជីដូនមួយបានណែនាំ។ ខ្លួនធ្លាប់ធ្វើការនៅខេត្តបាត់ដំបង តែដោយសារនៅទីនោះបានប្រាក់ខែតិចពេក ទើបខ្លួនមកបើករថយន្តដឹកអេតចាយនៅភ្នំពេញ វិញ។ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ ខ្លួនមកធ្វើការឲ្យថៅកែនៅភ្នំពេញ ដោយទទួលបានប្រាក់ខែ ២០០ដុល្លារអាមេរិកក្នុងមួយខែ មានលុយបាយ និងលុយជើងបន្ថែម។ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង១៩ និង០០ ខ្លួនបានបើករថយន្តដឹងកំប៉ុងអាលុយមីញ៉ូមគ្រីប ចំនួន ២៨តោន ទៅខេត្តប៉ៃលិន ដែលគេអ្នករៀបចំលើកដាក់ និងគ្របតង់ឲ្យរួចរាល់ ដោយពុំមានព្រូឡានទេ នៅថ្ងៃនោះផងដែរ ឈ្មោះ[redacted] សារ៉េន បានផ្ញើមនុស្សប្រុសម្នាក់ទៅ ខេត្តពោធិ៍សាត់ ហើយខ្លួនបានទៅយកមនុស្សនោះនៅម្តុំផ្លូវកប់ស្រូវ ហើយគាត់បានសុំខ្លួនចុះនៅម្តុំវត្តឬស្សីសាញ់ ដើម្បីយកលុយ ខ្លួនបានចាំគាត់ចុះទៅយកលុយមួយសន្ទុះក្រោយមកមនុស្សប្រុសនោះបានត្រឡប់មកវិញ ដោយបានផ្ញើផ្លែដូងឲ្យខ្លួនមួយផ្លែផង ពេលនោះខ្លួនមិនទាន់ហូបទេ ហើយខ្លួនបានឈប់នៅម្តុំផ្សារត្រាចហូបទឹកដូងនោះ ពេលភ្ញាក់ដឹងខ្លួនវិញ គឺនៅម្តុំចំការលើ ខេត្តកំពង់ចាម ហើយបាត់ឥវ៉ាន់អស់តែម្តង។ ពេលនោះខ្លួនបានខ្ចីទូរស័ព្ទគេខលទៅប្រាប់ឈ្មោះ ឌីណា គាត់ថាបាត់ឥវ៉ាន់អស់ហើយ។ ឈ្មោះ [redacted] សារ៉េន ជាអ្នកផ្ញើមនុស្សប្រុសនោះឲ្យជិះជាមួយខ្លួន អ្នកជិះជាមួយខ្លួននោះគឺជាមនុស្សប្រុសមិនមែនស្រីទេ។ ខ្លួនមិនបានស្គាល់អ្នកយកឥវ៉ាន់ និងឈ្មោះ [redacted] ចន្ថា ទេ។ ខ្លួនបានដឹងថាថៅកែបានដាក់GPS ក្នុងរថយន្ត តែពុំដឹងថាដាក់កន្លែងណាទេ ហើយពុំបានលួចកាត់ GPS ទេ។

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] លឹមអ៊ាង បានឆ្លើយថា ខ្លួនបានឲ្យជាងមកតម្លើង GPS ដាក់ក្នុងរថយន្តសម្រាប់ដឹងទំនិញ ស្របពេលនោះឈ្មោះ[redacted]វិច្ឆិកា ក៏បានមកទាន់ជាងកំពុងតម្លើងផងដែរ ហើយគាត់បានជជែកជាមួយជាងទៀតផង ពេលនោះខ្លួនបានប្រាប់ ឈ្មោះ [redacted] វិច្ឆិកា ក៏បស្លាកលេខឡានឲ្យមុនចេញដំណើរ ប៉ុន្តែ ឈ្មោះ [redacted] វិច្ឆិកា បានបដិសេធថាចាំគាត់កិបកន្លែងស្គាល់នៅ ខេត្តបាត់ដំបង។ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ខ្លួនបានឲ្យឈ្មោះ [redacted] វិច្ឆិកា ដឹកកំប៉ុងអាលុយមីញ៉ូមគ្រីបរួចចំនួន ២៨តោន ទៅខេត្តប៉ៃលិន។ លុះម៉ោង ៩ព្រឹក ស្រាប់តែ ឈ្មោះ[redacted]វិច្ឆិកា យកលេខថ្មីខលមកប្រាប់ ឈ្មោះ [redacted] ប៊ុណ្ណា ថាមានគេដាក់ថ្នាំយកឥវ៉ាន់អស់ហើយ ខ្លួនបានទៅកន្លែងកើតហេតុ និងប្តឹងសមត្ថកិច្ចដើម្បីឃាត់ខ្លួន ឈ្មោះ [redacted] វិច្ឆិកា។ ខ្លួនបានស្រាវជ្រាវតាមផ្លូវដោយសុំកាមេរ៉ាសុវត្ថិភាពដែល ឈ្មោះ [redacted] វិច្ឆិកា បានប្រាប់ថាមានអ្នកសុំដោយសារជិះឡានទៅជាមួយសុំចុះតាមផ្លូវដើម្បីទៅសុំលុយពីបងគាត់ ពេលត្រលប់មកវិញ គាត់បានយកដូងចំនួនពីរផ្លែ ក្រោយពេលឈ្មោះ[redacted] វិច្ឆិកា បានផឹកទឹកដូងនោះរួចលែងដឹងអី។ ខ្លួនបានដកឈ្មោះ [redacted] សារ៉េន ចេញដោយសារតែគាត់មិនគោរពកាងារ ដោយឡែកឈ្មោះ [redacted] ចន្ថា ខ្លួនពុំដែលស្គាល់ទេ។ លុះព្រឹកម៉ោង ៧ព្រឹក ខ្លួនឆែកGPS ឃើញនៅទីតាំងដដែល ហើយបានខលទៅ ឈ្មោះ [redacted]វិច្ឆិកា តែខលអត់លើក។ ខ្លួនប្តឹងទាមទារសំណងថ្លៃទំនិញអេតចាយចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក និងទាមទារជម្ងឺចិត្តចំនួន ២០,០០០(ពីរម៉ឺន)ដុល្លារអាមេរិក។

-សាក្សីឈ្មោះ[redacted] ម៉ាត់ បានឆ្លើយនាពេលសវនាការថា កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ៤រសៀល ខ្លួនកំពុងហូបបាយ ឈ្មោះ [redacted] សារ៉េន បើកឡានម៉ាកព្រុស ពណ៌ ឆ្នួត មកលេងនិងបបួលផឹកស្រាតែ ខ្លួនបដិសេធ ព្រោះមិនស្រួលខ្លួនរួច ឈ្មោះ [redacted] សារ៉េន បានសួរថាថ្ងៃនេះមានឡានដឹកអេតចាយទៅប្រទេសថៃ

ឬអត់ ខ្លួនឆ្លើយថាចាំមើលខ្លួនសួរអ្នកនៅឃ្លាំងសិនមួយសន្ទុះក្រោយមក ឈ្មោះ [redacted] សារ៉េន បានចេញឡានទៅវិញ ប្រហែលកន្លះម៉ោងមានលេខទូរស័ព្ទកន្ទុយ១១ ខលមកសួរខ្លួន ពេលនោះខ្លួនសួរថាបានលេខខ្លួនមកពីណា គេប្រាប់ថា ឈ្មោះ [redacted] ប៊ុនណ្ណា អ្នកឱ្យ។ ខ្លួនប្រាប់ថាពុំមានឡានដឹកអេតចាយចេញទៅថៃទេ តែមានឡានគ្នារបស់ខ្លួន ឈ្មោះ [redacted] វិច្ឆិកា ចេញទៅហើយខ្លួនបានឱ្យលេខទូរស័ព្ទ ឈ្មោះ [redacted] វិច្ឆិកា ទៅម្នាក់នោះ។

-តាមអំណានចម្លើយសាក្សី ឈ្មោះ [redacted] ប៊ុនណ្ណា បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង៤ រសៀល ឈ្មោះ [redacted] សារ៉េន បានទូរស័ព្ទបបួលខ្លួនផឹកស្រានៅដីវាល ហើយគាត់ចាំនៅទៅនោះ ខ្លួនបានឆ្លើយថាមកដល់ សាលាលេខ៥ ខេត្តកំពង់ឆ្នាំង លុះដល់ម៉ោង ៧យប់ ស្រាប់តែឈ្មោះ ម៉ក់ សារ៉េន ទូរស័ព្ទមកខ្លួនម្តងទៀតសួរថាមកដល់ណាហើយ ខ្លួនឆ្លើយថាមកដល់ឧដុង្គឡានស្ទះផ្លូវ លុះដល់ម៉ោង៧ និង៤៥ នាទីបានជួបឡានឈ្មោះ [redacted] វិច្ឆិកា នៅម្តុំព្រែកព្នៅ ពេលជិះហួសឡានបន្តិច ស្រាប់តែឈ្មោះ [redacted] សារ៉េន ទូរស័ព្ទមកខ្លួនម្តងទៀតសួរថាដល់ណាហើយ ពេលនោះខ្លួនឆ្លើយថាដល់ទំនប់កប់ស្រូវហើយ តែឈ្មោះ [redacted] សារ៉េន បែរជាប្រាប់ខ្លួនថាគាត់មិនបានមកទេ ព្រោះត្រូវជូនប្រពន្ធគាត់មកផ្ទះបងប្អូន។ ខ្លួនបានទៅដល់ដីវាលកន្លែងសម្រាប់ចតឡានពេលនោះម៉ោងប្រហែលជា ៨យប់ ស្រាប់តែមីងឈ្មោះ លី ដែលត្រូវជាម្តាយ ក្មេក ឈ្មោះ [redacted] វិច្ឆិកា បានទូរស័ព្ទមកខ្លួនថាគាត់ខលទៅ ឈ្មោះ [redacted] វិច្ឆិកា មិនលើកទេ ឱ្យខ្លួនខលទៅ ឈ្មោះ [redacted] វិច្ឆិកា ហេតុអីមិនលើកទូរស័ព្ទគាត់អញ្ចឹង ពេលនោះខ្លួនខលទៅឈ្មោះ [redacted] វិច្ឆិកា តែមិនលើកដូចគ្នា។ លុះដល់ម៉ោង ៨ ព្រឹក ស្រាប់តែឮដំណឹងថារថយន្តរបស់ ឈ្មោះ [redacted] វិច្ឆិកា ត្រូវគេដាក់ថ្នាំយកឥវ៉ាន់អស់។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង៧ និង០០ នាទី ឈ្មោះ [redacted] សារ៉េន បានទូរស័ព្ទមកខ្លួនតែមិនបានលើក លុះម៉ោង៧ និង៣៥ នាទី ឈ្មោះ [redacted] សារ៉េន បានខលមកខ្លួនម្តងទៀត ហើយសួរខ្លួនបាទថារឿងបាត់ឥវ៉ាន់ចាប់ចោរហើយ ឬនៅ ខ្លួនឆ្លើយថាមិនទាន់ចាប់បានទេ។

-តាមអំណាន របាយការណ៍លេខ ០១១/២១ របក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ របស់អធិការនគរបាលខណ្ឌដង្កោ បានបញ្ជាក់ថា កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង៧ និង០០ នាទី មានករណីលួច(លួចដែកកំប៉ុងអាលុយមីញ៉ូមគ្រីប) ត្រង់ចំណុចឃ្លាំងអេតចាយ ផ្លូវ២១៧ ស្ថិតនៅភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ជនរងគ្រោះឈ្មោះ [redacted] លឹមអ៊ាង បានឃាត់ខ្លួន ឈ្មោះ [redacted] វិច្ឆិកា ជាអ្នកបើករថយន្តដឹកកំប៉ុងអាលុយមីញ៉ូមគ្រីបរួចបានធ្វើឱ្យបាត់កំប៉ុងអាលុយមីញ៉ូមគ្រីបចំនួន ២៨តោនមានតម្លៃ ៥០,០០០ (ប្រាំម៉ឺន)ដុល្លារអាមេរិក ប្រគល់ឱ្យសមត្ថកិច្ចនគរបាលខណ្ឌដង្កោ ចាត់ការតាមផ្លូវច្បាប់។ ឈ្មោះ [redacted] លឹមអ៊ាង បានបំភ្លឺថានៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង៩ ឈ្មោះ [redacted] លឹមអ៊ាង បានហៅបុគ្គលិក ដែលជាអ្នកបើករថយន្តដឹកអេតចាយឱ្យគាត់ទាំងអស់មកជួបជុំគ្នានៅក្នុងឃ្លាំងអេតចាយ ស្ថិតនៅ ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីសួរនាំពាក់ព័ន្ធអំពីដំណើររឿងមុនពេលបាត់កំប៉ុងអាលុយមីញ៉ូម។ ពេលនោះបុគ្គលិកដែលជាអ្នកបើករថយន្តឱ្យគាត់មាន ទី០១.ឈ្មោះ [redacted] ប៊ុនណា បានប្រាប់ថាមុនថ្ងៃកើតហេតុមួយថ្ងៃគឺល្ងាចថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ឈ្មោះ [redacted] សារ៉េន ជាបុគ្គលិកចាស់ប្រើលេខទូរស័ព្ទ ០៩៧ ៣៩៣ ៧២៨៧ បានទូរស័ព្ទមក ឈ្មោះ [redacted] ប៊ុនណា ឱ្យមកភ្នំពេញ ប្រញាប់មកចង់ផឹកជាមួយគ្នា ពេលឈ្មោះ [redacted] ប៊ុនណា មកដល់ភ្នំពេញទូរស័ព្ទទៅប្រាប់ ឈ្មោះ [redacted] សារ៉េន ថាមកដល់ភ្នំពេញហើយ តែឈ្មោះ [redacted] សារ៉េន ប្រាប់ថាមិនបានជួបទេ។ ទី០៦.ឈ្មោះ [redacted] ម៉ាត់ ភេទប្រុស បានប្រាប់ថានៅល្ងាចថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ មុនពេលកើតហេតុ ឈ្មោះ ម៉ក់ សារ៉េន បានជិះរថយន្តម៉ាព្រុសមកជួបរូបគេនៅវត្តឬស្សីសាញ់ស្ថិតនៅភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីសួរនាំអំពីសកម្មភាពដែលរថយន្តដឹកកំប៉ុងអាលុយមីញ៉ូម ចេញទៅខេត្តប៉ៃលិន។ ទី០៣.

ឈ្មោះ [redacted] កុសល បានប្រាប់ថា នៅល្ងាចថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ឈ្មោះ [redacted] សារ៉េន បានទូរស័ព្ទសួរឈ្មោះ [redacted] កុសល ថាមានរថយន្តដឹកកំប៉ុងអាលុយមីញ៉ូមចេញទៅខេត្តណាដែរ ឬទេ? ឈ្មោះ [redacted] កុសល ប្រាប់ថាទៅសួរឈ្មោះ [redacted] ប៊ុនណា ទៅខ្លួនមិនដឹងទេ។ បន្ទាប់មកឈ្មោះ [redacted] វិច្ឆិកា ក៏បានបើករថយន្តដឹងកំប៉ុងអាលុយមីញ៉ូមចំនួន **២៨តោន** ចេញទៅខេត្តប៉ៃលិន នៅល្ងាចថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង១៩ និង០០ នាទីមានករណីចោលួចយកកំប៉ុងអាលុយមីញ៉ូមគ្រប់ទាំងនោះបាត់អស់តែម្តង។ ក្រោយកើតហេតុសមត្ថកិច្ច និងឈ្មោះ [redacted] **លីមអ៊ាង** បានទៅឆែកមើលកាមេរ៉ាសុវត្ថិភាពដែលបំពាក់នៅហាងមីហិលក្លូរ៉េតាមផ្លូវទំនប់កប់ស្រូវ ស្ថិតនៅសង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដែលជាទីតាំងឈ្មោះ [redacted] **វិច្ឆិកា** បានប្រាប់ថាទីតាំងខាងលើនេះមានបុរសម្នាក់មិនស្គាល់ឈ្មោះ ប្រើលេខទូរស័ព្ទ ០៨៨ ៨៩ ៣៩ ០១១ បានឈរចាំជិះរថយន្តទៅជាមួយ មានរថយន្តម៉ាកព្រូស ១គ្រឿង បើកតាមពីក្រោយរថយន្តដឹកកំប៉ុងអាលុយមីញ៉ូមនោះ ឈ្មោះ [redacted] **លីមអ៊ាង** ដឹងថារថយន្តម៉ាកព្រូសខាងលើជាកម្មសិទ្ធរបស់ ឈ្មោះ [redacted] **សារ៉េន** រួចសមត្ថកិច្ចនគរបាលខណ្ឌដង្កោ បានសុំឆែកលេខទូរស័ព្ទ ០៨៨ ៨៤ ៣៩ ០១១ កំណត់បានអត្តសញ្ញាណអ្នកប្រើប្រាស់មានឈ្មោះ [redacted] **ចិន្តា** ភេទស្រី។ ក្រោយពីធ្វើការបំភ្លឺរបស់ ឈ្មោះ [redacted] **លីមអ៊ាង** និងលទ្ធផលស្រាវជ្រាវបន្ថែមសមត្ថកិច្ចយើងបានសន្និដ្ឋានថាករណីខាងលើ មានការពាក់ព័ន្ធជាមួយ ឈ្មោះ [redacted] **សារ៉េន** និងឈ្មោះ [redacted] ចន្ថា តាមច្បាប់។

-លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] **លីមអ៊ាង** បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសាកសួរដេញដោល ឃើញថាកូនក្តីខ្លួនបានឱ្យ ឈ្មោះ [redacted] **វិច្ឆិកា** ដឹកកំប៉ុងអាលុយមីញ៉ូមទៅ ខេត្តប៉ៃលិន។ ក្រោយមកជនជាប់ចោទ ឈ្មោះ [redacted] **វិច្ឆិកា** បានប្រាប់ថាគេដាក់ថ្នាំយកឥវ៉ាន់អស់ហើយ ។ តាមចម្លើយរបស់ជនជាប់ចោទ ឈ្មោះ [redacted] **វិច្ឆិកា** និងចម្លើយរបស់សាក្សី ក៏ដូចជាចម្លើយរបស់កូនក្តីខ្លួន និងរបាយការណ៍លេខ ០១១/២១ របក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ របស់អធិការនគរបាលខណ្ឌដង្កោ ឃើញថាជនជាប់ចោទទាំង ៣នាក់ គឺពិតជាបានរួមគំនិតគ្នាប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោសពិតប្រាកដមែនមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ឈ្មោះ [redacted] **វិច្ឆិកា** ,ឈ្មោះ [redacted] **សារ៉េន** និងឈ្មោះ [redacted] ចន្ថា គ្រប់គ្រាន់ ហេតុនេះសូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ ក្នុងរឿងនេះកូនក្តីខ្លួនគឺជាជនរងគ្រោះបានប្តឹងទាមទារសំណងការបាត់បង់ទ្រព្យសម្បត្តិចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក និងសំណងជំងឺចិត្តចំនួន ២០,០០០(ពីរម៉ឺន)ដុល្លារអាមេរិក។

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា:** ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ, ស្តាប់ចម្លើយរបស់ជនជាប់ចោទ ឃើញថាមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ [redacted] **វិច្ឆិកា** ,ឈ្មោះ [redacted] **សារ៉េន** និងឈ្មោះ [redacted] ចន្ថា។ សូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនល្មើសតាមច្បាប់ និងសូមតម្កល់ដីកាសន្និដ្ឋានស្ថាពរ លេខ៤០៥១ អយដ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ទុកជាបានការដដែល។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] **វិច្ឆិកា** បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសាកសួរដេញដោលនាពេលសវនាការ និងចម្លើយសារភាពរបស់កូនក្តីខ្លួន ឃើញថាក្នុងរឿងនេះកូនក្តីខ្លួនក៏ជាជនរងគ្រោះ ដែលត្រូវបានជនល្មើសធ្វើកម្មភាពដាក់ថ្នាំក្នុងផ្លែម្លូងឱ្យកូនក្តីខ្លួនផឹក ហើយធ្វើសកម្មភាពលួចឥវ៉ាន់ ក្នុងរឿងនេះពុំមានភស្តុតាងដើម្បីដាក់បន្ទុកលើកូនក្តីខ្លួនថាបានលួចយកកំប៉ុងអាលុយមីញ៉ូមនោះទេ ហេតុនេះសូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ សម្រេចឱ្យកូនក្តីខ្លួន ឈ្មោះ [redacted] **វិច្ឆិកា** រួចផុតពីបទចោទប្រកាន់ដោយក្តីអនុគ្រោះ។



Scanned with CamScanner

-លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិជនជាប់ចោទ ឈ្មោះ [redacted] សារ៉េន និងឈ្មោះ [redacted] ចន្ថា បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសាកសួរដេញដោលនាពេលសវនាការ និងតាមចម្លើយរបស់ឈ្មោះ [redacted] វិច្ឆិកា និងចម្លើយដើមបណ្តឹង ,ចម្លើយរបស់សាក្សី ឃើញថាពុំមានភស្តុតាងដាក់បន្ទុកលើកូនក្តីខ្លួនគ្រប់គ្រាន់នោះទេ ម្យ៉ាងទៀតតាមចម្លើយរបស់ ឈ្មោះ [redacted] វិច្ឆិកា បានឆ្លើយថាបញ្ជាក់ថាអ្នកដែលឡើងជិះរថយន្តជាមួយខ្លួនគឺជាមនុស្សប្រុស មិនមែនមនុស្សស្រីទេ ប៉ុន្តែតាមការស្រាវជ្រាវលេខទូរស័ព្ទបង្ហាញថា ម្ចាស់លេខគឺជាមនុស្សស្រីមានឈ្មោះ [redacted] ចន្ថា ភេទស្រី ដែលផ្ទុយពីជាក់ស្តែង។ ហេតុនេះសូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្លួន ឈ្មោះ [redacted] សារ៉េន និងឈ្មោះ សាំង ចន្ថា រួចផុតពីបទចោទប្រកាន់ដោយក្តីអនុគ្រោះ។

-ជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា បាននិយាយសម្តីចុងក្រោយថា:សូមលោកចៅក្រមសម្រេចឱ្យខ្លួនរួចផុតពីបទចោទប្រកាន់។

-ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទ។
-ក្រោយពីបាន ស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី។
-ក្រោយពីបាន ស្តាប់ចម្លើយរបស់សាក្សី។
-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។
-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។
-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។
-ក្រោយពីបាន ស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ។
-ក្រោយពីបាន ពិនិត្យលើឯកសារ ភស្តុតាងនានា។
-ក្រោយពីបាន ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងរាជធានីភ្នំពេញ

## យល់ឃើញថា

១.កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង១៩ និង០០ នាទី ស្ថិតនៅចំណុច ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជនរងគ្រោះ ឈ្មោះ [redacted] លីមអ៊ាង ឱ្យជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា ដឹកកំប៉ុងអាលុយមីញ៉ូមគ្រីបរួចទម្ងន់ ២៨តោន មានតម្លៃ ៥0,000(ប្រាំម៉ឺន)ដុល្លារអាមេរិក ទៅខេត្តប៉ៃលិន ហើយជនត្រូវចោទ ឈ្មោះ [redacted] វិច្ឆិកា និងបក្សពួករួមមាន ឈ្មោះ[redacted] សារ៉េន បានសហការគ្នាលួចយកកំប៉ុងអាលុយមីញ៉ូមគ្រីបរបស់ជនរងគ្រោះទាំងអស់។ ក្រោយពេលកើតហេតុ ឈ្មោះ [redacted] វិច្ឆិកា បានខលទូរស័ព្ទប្រាប់ ឈ្មោះ [redacted] ប៊ុណ្ណា ថាខ្លួនត្រូវគេដាក់ថ្នាំយកប៉ុងអាលុយមីញ៉ូមគ្រីបអស់។

២.ជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា បានឆ្លើយនាពេលសវនាការថា ខ្លួនបានហៅជាងមកតម្លើង GPS ដាក់ក្នុងរថយន្តសម្រាប់ដឹងទំនិញ ស្របពេលនោះឈ្មោះ [redacted] វិច្ឆិកា ក៏បានមកទាន់ជាងកំពុងតម្លើងផងដែរ ហើយគាត់បានជជែកជាមួយជាងទៀតផង ហើយខ្លួនបានប្រាប់ឈ្មោះ [redacted] វិច្ឆិកា ក៏បស្តាកលេខឡានឱ្យមុនចេញដំណើរ ប៉ុន្តែឈ្មោះ [redacted] វិច្ឆិកា បានបដិសេធថាចាំគាត់កិបកន្លែងស្គាល់នៅ ខេត្តបាត់ដំបង។ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០២១ ខ្លួនបានឱ្យឈ្មោះ [redacted] វិច្ឆិកា ដឹកកំប៉ុងអាលុយមីញ៉ូមគ្រីបរួចចំនួន ២៨តោន ទៅខេត្តប៉ៃលិន។ លុះព្រឹកឡើង ម៉ោង ៩ព្រឹក ស្រាប់តែឈ្មោះ[redacted] វិច្ឆិកា យកលេខថ្មីខលមកប្រាប់ឈ្មោះ [redacted] ប៊ុណ្ណា ថាមានគេដាក់ថ្នាំយកឥវ៉ាន់អស់ហើយ ខ្លួនបានទៅកន្លែងកើតហេតុ និងប្តឹងសមត្ថកិច្ចដើម្បីឃាត់ខ្លួន ឈ្មោះ [redacted] វិច្ឆិកា។ ខ្លួនបានស្រាវជ្រាវតាមផ្លូវដោយសុំកាមេរ៉ាសុវត្ថិភាពដែលឈ្មោះ[redacted] វិច្ឆិកា បានប្រាប់ថាមានអ្នកសុំដោយសារជិះឡានទៅជាមួយសុំ

ចុះតាមផ្លូវ ដើម្បីទៅសុំលុយពីបងគាត់ ពេលត្រលប់មកវិញ គាត់បានយកដូងចំនួនពីរផ្លែ ក្រោយពេលឈ្មោះ[redacted] វិច្ឆិកា បានផឹកទឹកដូងនោះរួចលែងដឹងអី។ ខ្លួនបានដកឈ្មោះ[redacted]សារ៉េន ចេញដោយសារតែគាត់មិនគោរពការងារ ដោយឡែកឈ្មោះ [redacted] ចន្ថា ខ្លួនពុំដែលស្គាល់ទេ។ លុះព្រឹកម៉ោង ៧ព្រឹក ខ្លួនឆែកGPS ឃើញនៅទីតាំងដដែល ហើយបានខលទៅឈ្មោះ [redacted] វិច្ឆិកា តែខលអត់លើក។ខ្លួនប្ដឹងទាមទារសំណងថ្លៃទំនិញអេតចាយចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក និងទាមទារជម្ងឺចិត្តចំនួន ២០,០០០(ពីរម៉ឺន) ដុល្លារអាមេរិក។

៣.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] លឹមអ៊ាង បានឆ្លើយនាពេលសវនាការថា ខ្លួនបានឲ្យជាងមកតម្លើង GPS ដាក់ក្នុង រថយន្តសម្រាប់ដឹងទំនិញ ស្របពេលនោះឈ្មោះ [redacted] វិច្ឆិកា ក៏បានមកទាន់ជាងកំពុងតម្លើងផងដែរ ហើយគាត់បានជជែកជាមួយជាងទៀតផង ពេលនោះខ្លួនបានប្រាប់ ឈ្មោះ [redacted] វិច្ឆិកា ក៏បស្គាកលេខឡានឲ្យមុនចេញដំណើរ ប៉ុន្តែឈ្មោះ [redacted] វិច្ឆិកា បានបដិសេធថាចាំគាត់កិបកន្លែងស្គាល់នៅ ខេត្តបាត់ដំបង។ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ខ្លួនបានឲ្យឈ្មោ[redacted] វិច្ឆិកា ដឹកកំប៉ុងអាលុយមីញ៉ូមគ្រើបរួចចំនួន ២៨តោន ទៅខេត្តប៉ៃលិន។ លុះម៉ោង ៩ព្រឹក ស្រាប់តែ ឈ្មោះ[redacted] វិច្ឆិកា យកលេខថ្មីខលមកប្រាប់ ឈ្មោះ [redacted] ប៊ុណ្ណា ថាមានគេដាក់ថ្នាំយកឥវ៉ាន់អស់ហើយ ខ្លួនបានទៅកន្លែងកើតហេតុ និងប្ដឹងសមត្ថកិច្ចដើម្បីឃាត់ខ្លួន ឈ្មោះ[redacted] វិច្ឆិកា។ ខ្លួនបានស្រាវជ្រាវតាមផ្លូវដោយសុំកាមេរ៉ាសុវត្ថិភាពដែល ឈ្មោះ [redacted] វិច្ឆិកា បានប្រាប់ថាមានអ្នកសុំដោយសារជិះឡានទៅជាមួយសុំចុះតាមផ្លូវ ដើម្បីទៅសុំលុយពីបងគាត់ ពេលត្រលប់មកវិញ គាត់បានយកដូងចំនួនពីរផ្លែ ក្រោយពេលឈ្មោះ [redacted] វិច្ឆិកា បានផឹកទឹកដូងនោះរួចលែងដឹងអី។ ខ្លួនបានដកឈ្មោះ [redacted]សារ៉េន ចេញដោយសារតែគាត់មិនគោរពការងារ ដោយឡែកឈ្មោះ [redacted] ចន្ថា ខ្លួនពុំដែលស្គាល់ទេ។ លុះព្រឹកម៉ោង ៧ព្រឹក ខ្លួនឆែកGPS ឃើញនៅទីតាំងដដែល ហើយបានខលទៅ ឈ្មោះ [redacted] វិច្ឆិកា តែខលអត់លើក។ ខ្លួនប្ដឹងទាមទារសំណងថ្លៃទំនិញអេតចាយចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក និងទាមទារជម្ងឺចិត្តចំនួន ២០,០០០(ពីរម៉ឺន)ដុល្លារអាមេរិក។

៤.សាក្សីឈ្មោះ[redacted] ម៉ាត់ បានឆ្លើយនាពេលសវនាការថា កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ៤រសៀល ខ្លួនកំពុងតែហូបបាយស្រាប់ ឈ្មោះ [redacted] សារ៉េន បើកឡានម៉ាកព្រូស ពណ៌ ឆ្លូញ មកលេងខ្លួន និងបបួលខ្លួនផឹកតែខ្លួនមិនផឹកទេ ព្រោះខ្លួនមិនស្រួលខ្លួន រួចឈ្មោះ [redacted]សារ៉េន បានសួរខ្លួនថាថ្ងៃនេះមានឡានដឹកអេតចាយទៅប្រទេសថៃ ឬអត់ ពេលនោះខ្លួនឆ្លើយថាចាំមើលខ្លួនសួរអ្នកនៅឃ្លាំងសិន មួយសន្ទុះក្រោយមក ឈ្មោះ [redacted] សារ៉េន បានចេញឡានទៅវិញ ទៅប្រហែលកន្លះម៉ោងមនុស្សប្រុសមិនស្គាល់ឈ្មោះបានខលទូរស័ព្ទមានកន្ទុយ១១ ខលមកសួរខ្លួនពេលនោះខ្លួនសួរទៅបានលេខខ្លួនមកពីណា ពេលនោះគេប្រាប់ថាបានពីឈ្មោះ [redacted] ប៊ុនណ្ណា អ្នកឲ្យ។ ខ្លួនប្រាប់ថាពុំមានឡានដឹកអេតចាយចេញទៅថៃទេ តែមានរថយន្តរបស់គ្នាខ្លួនឈ្មោះ[redacted] វិច្ឆិកា ចេញទៅខេត្តប៉ៃលិន ហើយខ្លួនបានឲ្យលេខទូរស័ព្ទ ឈ្មោះ [redacted] វិច្ឆិកា ទៅម្នាក់នោះ។

៥.តាមអំណានចម្លើយសាក្សី ឈ្មោះ [redacted] ប៊ុនណ្ណា បានឆ្លើយនៅចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង៤ រសៀល ឈ្មោះ [redacted] សារ៉េន បានទូរស័ព្ទមកខ្លួនថាមកដល់ណាហើយគាត់ចាំនៅដីវាលដើម្បីផឹកស្រា ហើយខ្លួនបានឆ្លើយថាមកដល់សាលាលេខ៥ ខេត្តកំពង់ឆ្នាំង លុះដល់ម៉ោង ៧យប់ ស្រាប់តែឈ្មោះ [redacted]សារ៉េន ទូរស័ព្ទមកខ្លួនម្ដងទៀតថាមកដល់ណា ខ្លួនឆ្លើយថាមកដល់ឧដុង្គឡានស្ទះផ្លូវ លុះដល់ម៉ោង៧ និង ៤៥ នាទី ខ្លួនបានជួបឡានឈ្មោះ [redacted] វិច្ឆិកា នៅម្តុំព្រែកព្នៅ ពេលជិះហួសបន្តិចស្រាប់តែឈ្មោះ [redacted] សារ៉េន ទូរស័ព្ទមកខ្លួនម្ដងទៀតសួរថាដល់ណា ខ្លួនឆ្លើយថាដល់ទំនប់កប់ស្រូវ តែឈ្មោះ[redacted] សារ៉េន បែរជាប្រាប់ខ្លួនថាគាត់មិនបានមកទេ ព្រោះត្រូវជូនប្រពន្ធគាត់មកផ្ទះបងប្អូន លុះព្រឹកឡើងម៉ោង ៩ព្រឹក ស្រាប់តែឮដំណឹងថារថយន្តរបស់ ឈ្មោះ [redacted] វិច្ឆិកា ត្រូវគេដាក់ថ្នាំយកឥវ៉ាន់អស់។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ វេលា

ម៉ោង៧ និង០០ នាទីឈ្មោះ [redacted] សារ៉េត បានទូរស័ព្ទមកខ្លួនតែមិនបានលើក លុះម៉ោង៧ និង៣៥ នាទី ឈ្មោះ [redacted] សារ៉េន បានខលមកខ្លួនម្តងទៀត ហើយសួរខ្លួនថារឿងបាត់ឥវ៉ាន់ចាប់ចោរបានហើយឬនៅ ខ្លួនឆ្លើយថាមិនទាន់ចាប់បានទេ។

៦.តាមអំណាន របាយការណ៍លេខ ០១១/២១ របក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ របស់អធិការនគរបាលខណ្ឌដង្កោ បានបញ្ជាក់ថា ជនរងគ្រោះឈ្មោះ [redacted] លីមអ៊ាង បានបំភ្លឺថា នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង៩ ឈ្មោះ [redacted] លីមអ៊ាង បានហៅបុគ្គលិកដែលជាអ្នកបើករថយន្តដឹកអេតចាយឱ្យគាត់ទាំងអស់មកជួបជុំគ្នានៅក្នុងឃ្លាំងអេតចាយ ដើម្បីសួរនាំពាក់ព័ន្ធរឿងមុនពេលបាត់កំប៉ុងអាលុយមីញ៉ូម ។ ទី១. ឈ្មោះ [redacted] ប៊ុនណា បានប្រាប់ថាមុនថ្ងៃកើតហេតុមួយថ្ងៃគឺល្ងាចថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ឈ្មោះ [redacted] សារ៉េន ជាបុគ្គលិកចាស់ប្រើលេខទូរស័ព្ទ ០៩៧ ៣៩៣ ៧២៨៧ បានទូរស័ព្ទមក ឈ្មោះ [redacted] ប៊ុនណា ថាឱ្យមកភ្នំពេញប្រញ៉ាប់ មកចង់ផឹកជាមួយគ្នា ពេលឈ្មោះ [redacted] ប៊ុនណា មកដល់ភ្នំពេញ ទូរស័ព្ទទៅប្រាប់ឈ្មោះ [redacted] សារ៉េន ថាមកដល់ភ្នំពេញហើយ តែឈ្មោះ [redacted] សារ៉េន ប្រាប់ថាមិនបានជួបទេ ។ ទី០២.ឈ្មោះ [redacted] ម៉ាត់ បានប្រាប់ថានៅល្ងាចថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ មុនពេលកើតហេតុឈ្មោះ [redacted] សារ៉េន បានជិះរថយន្តម៉ាកព្រូសមកជួបរូបគេនៅវត្តឬស្សីសាញ់ ស្ថិតនៅភូមិប្រការ សង្កាត់ព្រៃស ដើម្បីសួរនាំអំពីសកម្មភាពដែលរថយន្តដឹកកំប៉ុងអាលុយមីញ៉ូម ចេញទៅខេត្តប៉ៃលិន។ ទី០៣.ឈ្មោះ [redacted] កុសល បានប្រាប់ថា នៅល្ងាចថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ឈ្មោះ [redacted] សារ៉េន បានទូរស័ព្ទសួរ ឈ្មោះ [redacted] កុសល ថាមានរថយន្តដឹកកំប៉ុងអាលុយមីញ៉ូមចេញទៅខេត្តណាដែរ ឬទេ ? ឈ្មោះ [redacted] កុសល ប្រាប់ថាឱ្យសួរឈ្មោះ [redacted] ប៊ុនណា ខ្លួនមិនដឹងទេ។ ឈ្មោះ [redacted] វិច្ឆិកា បានបើករថយន្តដឹងកំប៉ុងអាលុយមីញ៉ូមចំនួន **២៨តោន** ចេញទៅខេត្តប៉ៃលិន នៅល្ងាចថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង១៩ និង០០ នាទីមានករណីលួចយកកំប៉ុងអាលុយមីញ៉ូមគ្រីបទាំងនោះបាត់អស់តែម្តង។ ក្រោយពីកើតហេតុសមត្ថកិច្ចនិងឈ្មោះ [redacted] លីមអ៊ាង បានទៅឆែកមើលកាមេរ៉ាសុវត្ថិភាពដែលបំពាក់នៅហាងមីហិលក្លូវ៉េតាមផ្លូវទំនប់កប់ស្រូវស្ថិតនៅ សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដែលជាទីតាំងឈ្មោះ [redacted] វិច្ឆិកា បានប្រាប់ថាទីតាំងខាងលើនេះមានបុរសម្នាក់មិនស្គាល់ឈ្មោះ ប្រើលេខទូរស័ព្ទ ០៨៨ ៨៩ ៣៩ ០១១ បានឈរចាំជិះរថយន្តទៅជាមួយឃើញមានរថយន្តម៉ាកព្រូស ១គ្រឿង បើកតាមពីក្រោយរថយន្តដឹកកំប៉ុងនោះឈ្មោះ [redacted] លីមអ៊ាង ដឹងថារថយន្តម៉ាកព្រូសខាងលើ ជាកម្មសិទ្ធរបស់ ឈ្មោះ [redacted] សារ៉េន រួចសមត្ថកិច្ចនគរបាល ខណ្ឌដង្កោ បានសុំឆែកលេខទូរស័ព្ទ ០៨៨ ៨៤ ៣៩ ០១១ កំណត់បានអត្តសញ្ញាណអ្នកប្រើប្រាស់មាន ឈ្មោះ [redacted] ចន្ថា ភេទស្រី។ តាមលទ្ធផលស្រាវជ្រាវបន្ថែមសមត្ថកិច្ចបានសន្និដ្ឋានថាករណីខាងលើមានពាក់ព័ន្ធជាមួយ ឈ្មោះ [redacted] សារ៉េន និង ឈ្មោះ [redacted] ចន្ថា។

៧.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វិច្ឆិកា,ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីមអ៊ាង ,ចម្លើយរបស់សាក្សី ឈ្មោះ [redacted] ម៉ាត់ ,ចម្លើយរបស់សាក្សីឈ្មោះ [redacted] ប៊ុនណា និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ឃើញថាពិតជាមានអង្គហេតុ ដឹកកំប៉ុងអាលុយមីញ៉ូមគ្រីបរួចចំនួន **២៨តោន** តាមរថយន្តពីភ្នំពេញទៅខេត្តប៉ៃលិន តែនៅតាមបណ្តោយផ្លូវមានការលួចយកកំប៉ុងអាលុយមីញ៉ូមគ្រីបរួចចំនួន **២៨តោន** ពិតប្រាកដមែន ប៉ុន្តែអំពើលួចនេះពុំមានការប្រើប្រាស់ហិង្សាលើម្ចាស់ទ្រព្យ ឬ មានការកាន់កាប់គាស់ទម្លុះទម្លាយគ្រឿងបិទជិតបើកទ្វារ ដែលមានស្ថានទម្ងន់ក្នុងអំពើលួចនោះទេ។

៨.តាមចម្លើយរបស់ជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា , ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] លីមអ៊ាង, ចម្លើយរបស់សាក្សីឈ្មោ[redacted] ម៉ាត់ ,ចម្លើយរបស់សាក្សីឈ្មោះ [redacted] ប៊ុនណា ឃើញ



Scanned with CamScanner

ថាជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា គឺជាតៃកុងឡាន ដែលបានបើករថយន្តដឹកកំប៉ុងអាលុយមីញ៉ូមគ្រីបរួចពីឃ្លាំងទៅខេត្តប៉ៃលិន ហើយជនជាប់ចោទរូបនេះបានដឹងថារថយន្តរបស់ខ្លួនមានបំពាក់GPS។ ក្រោយពេលកើតហេតុជនជាប់ចោទឈ្មោះ [redacted] វិច្ឆិកា បានប្រាប់ថាមានគេដាក់ថ្នាំយកឥវ៉ាន់ ពីលើរថយន្តហើយបានបើករថយន្តយកមកប្តុងចោលម្តុំចំការលើ ខេត្តកំពង់ចាម ពិតមែន ប៉ុន្តែក្រោយពីសមត្ថកិច្ចឃាត់ខ្លួនជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា ឃើញថាជនជាប់ចោទរូបនេះពុំមានអាការៈត្រូវថ្នាំសណ្តំរបស់គេនោះទេ, ម្យ៉ាងវិញទៀតរថយន្តត្រូវបានកាត់ផ្តាច់GPS ដែលអំពើនេះអាចបញ្ជាក់បានថាជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា ដែលជាតៃកុងពិតជាបានចូលរួមក្នុងសកម្មភាពលួចកំប៉ុងអាលុយមីញ៉ូមគ្រីបរួចចំនួន ២៨តោន របស់ជនរងគ្រោះពិតមែន។

៩.តាមចម្លើយរបស់ជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា, ចម្លើយរបស់សាក្សីឈ្មោះ [redacted] ម៉ាត់ ឃើញថានៅថ្ងៃកើតហេតុជនជាប់ចោទ ឈ្មោះ [redacted] សារ៉េន បានទាក់ទងមកឈ្មោះ [redacted] ម៉ាត់ ចង់ដឹងមានរថយន្តចេញ ហើយនៅពេលនោះឈ្មោះ [redacted] សារ៉េន បានផ្ញើមនុស្សទៅជិះតាមរថយន្ត ទៅខេត្តពោធិ៍សាត់ ក្រោយមកមានមនុស្សប្រុសម្នាក់បានខលទូរស័ព្ទមានលេខ ០៨៨ ៨៤៣ ៩០១១ ខលមកតៃកុងឡានសុំឡានជិះទៅខេត្តពោធិ៍សាត់ ឈ្មោះ [redacted] វិច្ឆិកា បានដឹកអ្នកសុំជិះនោះទៅជាមួយ។ នៅថ្ងៃកើតហេតុនោះដែរជនជាប់ចោទ ឈ្មោះ [redacted] សារ៉េន បានល្បួងឈ្មោះ [redacted] ម៉ាត់ ចង់បានព័ត៌មានឡានដឹកឥវ៉ាន់ចេញពីឃ្លាំងដោយធ្វើជាបបួល ឈ្មោះ [redacted] ម៉ាត់ ផឹក និងសុំផ្ញើមនុស្សទៅខេត្តពោធិ៍សាត់ ប៉ុន្តែក្រោយពេលរូបគេផ្ញើមនុស្ស ទៅខេត្តពោធិ៍សាត់ និងដឹកថារថយន្តបានចេញពីឃ្លាំងរួចហើយឈ្មោះ [redacted] សារ៉េន បានប្រាប់ឈ្មោះ [redacted] ម៉ាត់ វិញថារវល់រំសាយការជួបផឹកស៊ីនោះ សរបញ្ជាក់ឲ្យឃើញថាជនជាប់ចោទ ឈ្មោះ [redacted] សារ៉េន ពិតជាបានចូលរួមយ៉ាងសកម្មក្នុងការរៀបគម្រោងយកកំប៉ុងអាលុយមីញ៉ូមគ្រីបរួចចំនួន **២៨តោន** របស់ជនរងគ្រោះ។

១០.តាមចម្លើយរបស់ជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា, ចម្លើយរបស់សាក្សីឈ្មោះ [redacted] ម៉ាត់ ,ចម្លើយរបស់សាក្សីឈ្មោះ [redacted] ប៊ុនណ្ណា ក៏ដូចជាលទ្ធផលនៃការឆែកលេខទូរស័ព្ទ ០៨៨ ៨៤៣៩០១១ ឃើញជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា ក៏ដូចជាសាក្សីបានឆ្លើយស៊ីសង្វាក់គ្នាបញ្ជាក់ថាម្ចាស់លេខ ០៨៨ ៨៤៣៩ ០១១ ដែលទាក់ទងសុំឡាន ឈ្មោះ [redacted] វិច្ឆិកា ជិះទៅខេត្តពោធិ៍សាត់ គឺជាមនុស្សប្រុស ប៉ុន្តែតាមលទ្ធផលស្រាវជ្រាវអត្តសញ្ញាណម្ចាស់លេខទូរស័ព្ទ ឃើញថាលេខទូរស័ព្ទ ០៨៨ ៨៤៣៩ ០១១ គឺមានម្ចាស់ឈ្មោះ [redacted] ចន្ថា ភេទស្រីទៅវិញ។ ទោះជាការឆែកលេខទូរសព្ទ័ ០៨៨ ៨៤៣៩០១១ ឃើញថាភេទស្រីក៏ពិតមែន ប៉ុន្តែតាមចម្លើយជនជាប់ចោទ ក៏ដូចជាសាក្សីបញ្ជាក់ថាអ្នកដែលជិះឡានទៅ ខេត្តពោធិ៍សាត់ គឺជាមនុស្សប្រុស ដូច្នេះអាចបញ្ជាក់បានថា ឈ្មោះ [redacted] ចន្ថា ភេទស្រី ពុំបានប្រព្រឹត្តអំពើ លួចកំប៉ុងអាលុយមីញ៉ូមគ្រីបរួច ចំនួន **២៨តោន** របស់ជនរងគ្រោះនោះទេ ផ្អែកតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺបុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះតាមបញ្ញត្តិមាត្រា២៤ នៃក្រមព្រហ្មទណ្ឌ។

១១.អំពើរបស់ជនជាប់ចោទ ឈ្មោះ [redacted] ចន្ថា ភេទស្រី ពុំមានភស្តុតាង និងពុំមានធាតុផ្សំគ្រប់គ្រាន់ពីបទ **លួចមានស្ថានទម្ងន់ទោស** ហេតុនេះគប្បីសម្រេចឲ្យជនជាប់ចោទរូបនេះ រួចខ្លួនពីបទចោទប្រកាន់បទ **លួចមានស្ថានទម្ងន់ទោស**។

១២.គ្មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើ ឈ្មោះ [redacted] ចន្ថា ភេទស្រី ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

១៣.នៅដំណាក់កាលចៅក្រមស៊ើបសួរបានចេញដីកាចាប់ខ្លួន ឈ្មោះ [redacted] ចន្ថា ភេទស្រី តាមដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៧៣០ "ស"ដចន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ គប្បីតុលាការសម្រេចឱ្យបញ្ឈប់ធ្វើការចាប់ខ្លួន ឈ្មោះ [redacted] ចន្ថា។

**១៤.**តាមសំអាងហេតុចំណុចទី៧ ,ទី៨ និងទី៩ ខាងលើឃើញថាអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **វិច្ឆិកា** និងឈ្មោះ [redacted] **សារ៉េន** ដែលបានលួចយកដែកកំប៉ុងអាលុយមីញ៉ូមគ្រីបរួចចំនួន **២៨តោន** របស់ជនរងគ្រោះ គឺជាបទល្មើសលួច ដូច្នេះគប្បីធ្វើការកែប្រែបទចោទប្រកាន់ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចភូមិម័លសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

**១៥.**ជនជាប់ចោទ ឈ្មោះ [redacted] **វិច្ឆិកា** និងឈ្មោះ [redacted] **សារ៉េន** ក្នុងពេលប្រព្រឹត្តបទល្មើសជននេះមានសមត្ថភាពលទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវនូវអំពើល្មើសរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

**១៦.**អំពើរបស់ជនជាប់ចោទ ឈ្មោះ [redacted] **វិច្ឆិកា** និងឈ្មោះ [redacted] **សារ៉េន** បានបង្ហាញឱ្យឃើញថាគ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្តក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទមានចេតនាទុច្ចរិតដែលការប្រព្រឹត្តនេះធ្វើឱ្យខូចនូវរបៀបរៀបរយសាធារណៈសណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់នីត្យានុកូលភាពសង្គម និងបំពានលើមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**១៧.**មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើ ឈ្មោះ [redacted] **វិច្ឆិកា** និងឈ្មោះ [redacted] **សារ៉េន** ពីបទ លួចប្រព្រឹត្តនៅចំណុច ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

១៨.ជនជាប់ចោទ ឈ្មោះ [redacted] **វិច្ឆិកា** ពេលដែលរូបគេប្រព្រឹត្តបទល្មើសហើយជនជាប់ចោទរូបនេះមានកម្រិតវប្បធម៌ទាប ស្ថិតក្នុងគ្រួកូលក្រីក្រ ហើយជីវប្រវត្តកន្លងមករូបគេពុំធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសម្តងណាឡើយ ឡើយគប្បីតុលាការលើកយកមកពិចារណា។

១៩.ជនជាប់ចោទ ឈ្មោះ [redacted] **សារ៉េន** ក្រោយពេលប្រព្រឹត្តបទល្មើសរួច បានរត់គេចខ្លួនបាត់ទាំងនេះសបញ្ជាក់ឱ្យឃើញថាជនជាប់ចោទរូបនេះ មានចេតនាទុច្ចរិតគេចវេសពីការទទួលខុសត្រូវចំពោះមុខច្បាប់ គ្មានស្មារតីភ្ញាក់រលឹកចង់កែប្រែខ្លួនឱ្យក្លាយជាមនុស្សល្អ ដើម្បីរួមរស់ក្នុងសង្គមឡើយ គប្បីចាប់ខ្លួនជននេះយកមកអនុវត្តទោស តាមអំណាចសាលក្រមនេះ។

**២០.**ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] **លឹមអ៊ាង** បានប្តឹងទាមទារសំណងរដ្ឋប្បវេណី ចំនួន **៥០,០០០** (ប្រាំម៉ឺន)ដុល្លារអាមេរិក និងសំណងជម្ងឺចិត្ត **២០,០០០**(ពីរម៉ឺន)ដុល្លារអាមេរិក ហេតុនេះគប្បីតុលាការពិចារណាក្នុងការសម្រេចសេចក្តី។

**២១.**ព្យសនកម្ម ដែលកើតមានចំពោះជនរងគ្រោះបណ្តាលឱ្យខូចខាត និងប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះកើតឡើងដោយសារអំពើរបស់ជនជាប់ចោទ ឈ្មោះ [redacted] **វិច្ឆិកា** និងឈ្មោះ [redacted] **សារ៉េន** ដូច្នេះជនជាប់ចោទរូបនេះត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាត និងសំណងជំងឺចិត្តដល់ជនរងគ្រោះ។

**២២.**សេចក្តីសន្និដ្ឋានរបស់ លោកមេធាវី [redacted] ការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យតុលាការផ្តល់សំណងរដ្ឋប្បវេណី ចំនួន **៥០,០០០**(ប្រាំម៉ឺន)ដុល្លារអាមេរិក និងសំណងជម្ងឺចិត្ត **២០,០០០**(ពីរម៉ឺន)ដុល្លារអាមេរិក គប្បីតុលាការពិចារណាក្នុងការសម្រេចសេចក្តី។



Scanned with CamScanner

២៣.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានតម្កល់បទចោទប្រកាន់ និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

២៤.សេចក្តីសន្និដ្ឋានរបស់ លោកមេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា សុំឱ្យតុលាការសម្រេចឱ្យកូនក្តីរួចខ្លួនពីបទចោទប្រកាន់ គប្បីតុលាការពិចារណាក្នុងការសម្រេចសេចក្តី។

២៥.សេចក្តីសន្និដ្ឋានរបស់ លោកមេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] សារ៉េន និងឈ្មោះ [redacted] ចន្ថា សុំឱ្យតុលាការសម្រេចឱ្យកូនក្តីរួចខ្លួនពីបទចោទប្រកាន់ គប្បីតុលាការពិចារណាក្នុងការសម្រេចសេចក្តី។

២៦.ជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា និយាយសំដីចុងក្រោយថាសូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យខ្លួនរួចផុតពីបទចោទប្រកាន់ គប្បីតុលាការពិចារណាក្នុងការសម្រេចសេចក្តី។

**<u>ហេតុដូច្នេះសម្រេច</u>**

១.ឱ្យឈ្មោះ [redacted] ចន្ថា ភេទស្រី អាយុ៣៥ ឆ្នាំ សញ្ជាតិ ខ្មែរ រួចខ្លួនពីបទចោទប្រកាន់ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុច ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ចាប់ពីពេលនេះតទៅតាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២.កែប្រែបទចោទប្រកាន់លើ** ឈ្មោះ [redacted] វិច្ឆិកា និងឈ្មោះ [redacted] សារ៉េន ពីបទ **លួចមានស្ថានទម្ងន់ទោស** ទៅបទ **លួច** ប្រព្រឹត្តនៅចំណុចភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**៣.ផ្តន្ទាទោស:**

៣.១.ឈ្មោះ [redacted] វិច្ឆិកា ភេទប្រុស អាយុ២៩ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **២(ពីរ)ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **១,០០០,០០០(មួយលាន)រៀល**។

៣.២.ឈ្មោះ [redacted] **សារ៉េន** ភេទប្រុស អាយុ៣៩ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **៣(បី)ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **១,០០០,០០០(មួយលាន)រៀល**។

ពីបទ **លួច** ប្រព្រឹត្តនៅចំណុច ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**៤.បង្គាប់ឱ្យចាប់ខ្លួននិងឃុំខ្លួនឈ្មោះ [redacted] សារ៉េន** ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ។

**៥.បញ្ឈប់ការចាប់ខ្លួន** ឈ្មោះ [redacted] ចន្ថា (តាមដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៧៣០"ស"ដចន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ)។

**៦.បង្គាប់ឱ្យជនជាប់ចោទ** ឈ្មោះ [redacted] វិច្ឆិកា និងឈ្មោះ [redacted] សារ៉េន រួមគ្នាសងប្រាក់ចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក និងសំណងជំងឺចិត្តចំនួន ២០,០០០,០០០(ម្ភៃលាន)រៀល ឱ្យទៅឈ្មោះ [redacted] **លឹមអ៊ាង**។ ការទាមទារលើសពីនេះច្រានចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៧ **ខែកុម្ភៈ ឆ្នាំ២០២២** ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted] វិច្ឆិកា និងកំបាំងមុខជនជាប់ចោទ ឈ្មោះ [redacted] សារ៉េន និងឈ្មោះ [redacted] ចន្ថា ,ចំពោះមុខមេធាវីការពារ



Scanned with CamScanner

ឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២។ ភាគីមានសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

..............................................................................................................................................

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ ព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]